# ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី
# "ចាយលើកដំបូងជាមួយអ៊ីអនកាតទទួលបានទឹកប្រាក់ត្រឡប់មកវិញ ១០០%"
# បញ្ញត្តិនិងលក្ខខណ្ឌ

**<u>និយមន័យ៖</u>**

- អ៊ីអន អេសភីប៊ី៖ សំដៅទៅលើ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី។
- ប្រូម៉ូសិន៖ សំដៅទៅលើ "ចាយលើកដំបូងជាមួយអ៊ីអនកាតទទួលបានទឹកប្រាក់ត្រឡប់មកវិញ ១០០%" ដែលរៀបចំដោយ អ៊ីអន អេសភីប៊ី ស្របតាមលក្ខខណ្ឌដែលបានកំណត់ នាពេលនេះ។
- ម្ចាស់កាតដែលមានសិទ្ធិ៖ សំដៅទៅលើម្ចាស់អ៊ីអនកាតថ្មីទាំងអស់ មានលេខសម្គាល់អតិថិជនថ្មី ដែលធ្វើការចំណាយលើកដំបូងជាមួយប្រតិបត្តិការជោគជ័យ (មិនរួមបញ្ចូលអតិថិជនដែលប្រើប្រាស់កាតបន្ថែម & បុគ្គលិករបស់ អ៊ីអន អេសភីប៊ី) ក្នុងអំឡុងពេលប្រូម៉ូសិន លើកលែងតែម្ចាស់កាតដែលគណនីកាតត្រូវបានផ្អាក លុបចោល ឬបិទដោយហេតុផលណាមួយក្នុងអំឡុងពេលប្រូម៉ូសិន។

**<u>រយៈពេលប្រូម៉ូសិន៖</u>**

ប្រូម៉ូសិននេះចាប់ផ្តើមពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៥ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៥ ("រយៈពេលប្រូម៉ូសិន") រួមបញ្ចូលទាំងថ្ងៃបុណ្យជាតិ ឬបន្តទៅរយៈពេលផ្សេងទៀតដោយកំណត់តាមការសម្រេចចិត្តតែមួយគត់ និងដាច់ខាតរបស់ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី ដោយមិនចាំបាច់ជូនដំណឹងទៅម្ចាស់អ៊ីអនកាតដែលមានសិទ្ធិជាមុន។

**<u>លក្ខខណ្ឌដែលមានអត្ថិភាព៖</u>**

| ម្ចាស់កាតដែលមានសិទ្ធិ | កាលបរិច្ឆេទបើកដំណើរការកាត | កាលបរិច្ឆេទធ្វើប្រតិបត្តិការ | ការចំណាយជាអប្បបរមាក្នុងមួយប្រតិបត្តិការ | ទឹកប្រាក់ផ្តល់ជូនត្រឡប់វិញសម្រាប់ម្ចាស់អ៊ីអនកាតម្នាក់ | កាលបរិច្ឆេទផ្តល់ទឹកប្រាក់ត្រឡប់វិញ |
|---|---|---|---|---|---|
| ត្រូវជាម្ចាស់អ៊ីអនកាតថ្មី មានលេខសម្គាល់អតិថិជនថ្មី | ចាប់ពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៥ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ ២០២៥ | ត្រូវធ្វើការចំណាយលើកដំបូងក្នុងអំឡុងពេល ១៤ថ្ងៃបន្ទាប់ពីបើកដំណើរការកាត | មិនកំណត់ចំនួនចំណាយណាមួយ | ទឹកប្រាក់ត្រឡប់មកវិញ ១០០% ឬអតិបរមាត្រឹម ៥ដុល្លារ | ទឹកប្រាក់ត្រឡប់វិញនឹងត្រូវដាក់បញ្ចូលទៅក្នុងគណនីរបស់ម្ចាស់អ៊ីអនកាតក្នុងអំឡុងពេល ១៤ថ្ងៃនៃថ្ងៃធ្វើការនាខែបន្ទាប់ |

**<u>លក្ខខណ្ឌប្រូម៉ូសិន៖</u>**

- អតិថិជនថ្មីដែលជាម្ចាស់អ៊ីអនកាតដើម ធ្វើការចំណាយជាមួយអ៊ីអនកាតក្នុងអំឡុងពេល ១៤ ថ្ងៃ (ប្រតិទិន) បន្ទាប់ពីធ្វើការបើកដំណើរការកាតនឹងទទួលបានទឹកប្រាក់ត្រឡប់មកវិញ ១០០% ។
- ប្រូម៉ូសិនមិនរាប់បញ្ចូលអតិថិជនកាតបន្ថែម បុគ្គលិករបស់អ៊ីអន អេសភីប៊ី បុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនអ៊ីអន កាតបន្តសុពលភាព និងកាតជំនួសឡើយ។

- ការចំណាយត្រូវធ្វើឡើងដោយប្រើប្រាស់អ៊ីអនកាត (រួមបញ្ចូលទាំងការទិញទំនិញអនឡាញ) ឬស្កេនតាមរយៈអ៊ីអនកាតម៉ូបាលនៅគ្រប់ហាងពាណិជ្ជករដែលមានទទួលការទូទាត់តាមរយៈអ៊ីអនកាតជាមួយប្រតិបត្តិការជោគជ័យប៉ុណ្ណោះ។
- ទឹកប្រាក់ត្រឡប់មកវិញនឹងផ្តល់ជូនម្តងប៉ុណ្ណោះសម្រាប់ម្ចាស់អ៊ីអនកាតដើមម្នាក់ក្នុងអំឡុងពេលប្រូម៉ូសិន។
- ទឹកប្រាក់ដែលផ្តល់ជូនត្រឡប់មកវិញជាអតិបរមាគឺត្រឹម ៥ដុល្លារក្នុងអំឡុងពេលប្រូម៉ូសិន។
- ទឹកប្រាក់ដែលផ្តល់ជូនត្រឡប់មកវិញនឹងត្រូវដាក់បញ្ចូលទៅក្នុងគណនីម្ចាស់អ៊ីអនកាតក្នុងអំឡុងពេល ១៤ថ្ងៃ នៃថ្ងៃធ្វើការនាខែបន្ទាប់។
- អ៊ីអន អេសភីប៊ី នឹងធ្វើការផ្ញើសារជូនដំណឹងដល់ម្ចាស់អ៊ីអនកាតដើមដែលលមានសិទ្ធិ បន្ទាប់ពីអ៊ីអន អេសភីប៊ី បានបញ្ចូលទឹកប្រាក់ត្រឡប់មកវិញទៅក្នុងគណនីរួចរាល់។
- ការផ្តល់ជូននេះមិនអាចផ្លាស់ប្តូរទៅជាប្រាក់ ឬទំនិញផ្សេងៗបាននោះទេ។

**<u>ការដកសិទ្ធិ៖</u>**

អ៊ីអន អេសភីប៊ី រក្សាសិទ្ធិដាច់ខាតក្នុងការដកសិទ្ធិចូលរួមរបស់ម្ចាស់កាតដែលមានសិទ្ធិណាមួយ ដោយមិនចាំបាច់ជូនដំណឹងជាមុនក្នុងករណី៖

(ក) គណនីរបស់ម្ចាស់កាតដែលមានសិទ្ធិស្ថិតនៅក្នុងលំនាំដើម (ព័ត៌មានលម្អិតនៃ "លំនាំដើម" សូមចុចលើតំណភ្ជាប់ (TCs-AEONCARD-EN & TCs-AEONCARD-KH)ក្នុងអំឡុងពេលប្រូម៉ូសិន ឬ

(ខ) គណនីរបស់ម្ចាស់កាតដែលមានសិទ្ធិប៉ុន្តែត្រូវបានបិទក្នុងអំឡុងពេលប្រូម៉ូសិន ឬ

(គ) ម្ចាស់កាតដែលមានសិទ្ធិបានផ្តល់ព័ត៌មានមិនពិត ឬប្រព្រឹត្តបទល្មើសក្នុងរបៀបណាមួយក្នុងអំឡុងពេលប្រូម៉ូសិន ឬ

(ឃ) ម្ចាស់កាតដែលមានសិទ្ធិបានរំលោភលើលក្ខខណ្ឌណាមួយដែលមានចែងនៅទីនេះ។

**<u>ការទទួលខុសត្រូវ៖</u>**

អ៊ីអន អេសភីប៊ី នឹងមិនទទួលខុសត្រូវចំពោះអ្នកចូលរួមចំពោះការខូចខាតណាមួយដែលមានលក្ខណៈ ឬការខាតបង់ណាមួយដែលទទួលរង (រួមទាំង ប៉ុន្តែមិនកំណត់ចំពោះការបាត់បង់ឆន្ទៈសុច្ឆរិត ប្រាក់ចំណូល ឬប្រាក់ចំណេញ ឬជាលទ្ធផល ដោយផ្ទាល់ ឬដោយប្រយោល គំរូ ចៃដន្យ ការដាក់ទណ្ឌកម្ម ឬការខូចខាតពិសេស) ទោះបីជាកើតឡើងទាក់ទងនឹងការចូលរួមក្នុងប្រូម៉ូសិន ឬ ធនាគារឯកទេស អ៊ីអន (ខេមបូឌា) ភីអិលស៊ី អនុវត្តសិទ្ធិរបស់ខ្លួនដោយអនុលោមតាមលក្ខខណ្ឌណាមួយនៅទីនេះ។

**<u>ជាទូទៅ៖</u>**

1) ការសម្រេចរបស់ អ៊ីអន អេសភីប៊ី លើរាល់បញ្ហាដែលពាក់ព័ន្ធនឹងប្រូម៉ូសិននេះគឺការចងកាតព្វកិច្ច និងការសម្រេចជាចុងក្រោយ ហើយនឹងមិនមានការឆ្លើយឆ្លងបន្ថែមដើម្បីកែប្រែ ឬការកែប្រែពីភាគីដទៃទៀតនោះទេ។ រាល់លក្ខខណ្ឌដែលមានចែងនៅទីនេះត្រូវបានគ្រប់គ្រង និងបកស្រាយដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា។
2) អ្នកចូលរួមទាំងអស់បានអាន និងយល់ពីរាល់លក្ខខណ្ឌដែលបានបញ្ជាក់នៅទីនេះ ហើយ អ៊ីអន អេសភីប៊ី មានសិទ្ធិផ្តាច់មុខក្នុងការផ្អាកបញ្ចប់ ឬលុបចោលប្រូម៉ូសិននៅពេលណាមួយដោយគ្មានហេតុផល និងដោយមិនចាំបាច់ជូនដំណឹងជាមុនទៅអតិថិជនដូចដែលបានបញ្ជាក់នៅលើគេហទំព័រអ៊ីអន អេសភីប៊ី www.aeon.com.kh
3) សម្រាប់ការណែនាំ និង/ឬមតិយោបល់ពាក់ព័ន្ធនឹងប្រូម៉ូសិននេះ សូមទាក់ទងមកកាន់លេខទូរស័ព្ទទាន់ហេតុការណ៍របស់អ៊ីអន អេសភីប៊ី តាមរយៈទូរស័ព្ទទៅលេខ ០២៣/០៧០/០៧៨ ៩៨៨ ៥៥៥។